# ៦. កែសម្រួលការអប់រំឱ្យស្របតាមតម្រូវការ

គេឃើញមានការកែប្រែសំខាន់ៗមួយចំនួនទាក់ទងនឹងកុមារពិការនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ នេះគឺជានិន្នាការទទួលស្គាល់ថា ប្រព័ន្ធអប់រំត្រូវតែកែប្រែទៅតាមតម្រូវការរបស់កុមារជាជាងបង្ខំកុមារឲ្យកែប្រែ និងសម្របខ្លួនឲ្យត្រូវតាមការអប់រំដែលរដ្ឋកំពុងតែផ្តល់ឲ្យ។

ការប្រើប្រាស់ពាក្យ "ពិការ" នៅទសវត្សរ៍កន្លងមកត្រូវបានដូរឲ្យប្រើពាក្យ "តម្រូវការពិសេស" នៅពេលបច្ចុប្បន្ន ដើម្បីបញ្ជាក់អំពីការពិតដែលថា កុមារត្រូវរួមបញ្ចូលទាំងកុមារដែលរៀនឆាប់ចេះ និងកុមារដែលរៀនខ្សោយ ហើយថាគ្មាន "ពាក្យ" ណាមួយដែលអាចវាស់សមត្ថភាពរបស់កុមារបានទេ។ ដូច្នេះហេតុផលសមរម្យបំផុតគឺចាត់ទុកកុមារជាបុគ្គលដាច់ដោយឡែកពីគ្នា ដូចដែលសិទ្ធិមនុស្សអន្តរជាតិតម្រូវឲ្យមានជាជាងការរៀបចំកម្មវិធីអប់រំសំរាប់ "កុមាររៀនមធ្យម" ដែលមិនមាននោះទេ។

ការខកខានមិនបានទទួលការអប់រំដែលមានគុណភាពគឺជាការបាត់បង់ឱកាសការងារ និងធ្វើឲ្យភាពក្រីក្រចេះតែកើនឡើង។ ទោះបីជាយ៉ាងណាក៏ដោយ ការអប់រំតែមួយមិនអាចធ្វើឲ្យកុមារគេចចេញពីភាពក្រីក្របានទេ។ ការអប់រំផ្អែកលើសិទ្ធិព្យាយាមបន្សីផ្នែកផ្សេងៗឲ្យចូលគ្នា (ដូចជា ការអប់រំ និងការងារ) នៅក្នុងក្របខ័ណ្ឌរួមមួយ។ ក្របខ័ណ្ឌនេះកើតចេញពីសិទ្ធិមនុស្សដែលទទួលស្គាល់ជាសកល។ ពីព្រោះសិទ្ធិមនុស្សមានទំនាក់ទំនងគ្នា និងពឹងពាក់គ្នាទៅវិញទៅមក ការមានសិទ្ធិទទួលការអប់រំនឹងនាំទៅដល់ការប្រើប្រាស់សិទ្ធិមនុស្សលើផ្នែកផ្សេងទៀត។ ប្រសិនជាសិទ្ធិអប់រំត្រូវបានបដិសេធ សិទ្ធិផ្សេងទៀតក៏គ្មានដែរ។ ដូច្នេះ ការអប់រំផ្អែកលើសិទ្ធិមានន័យទូលំទូលាយណាស់។ វាមិនមែនគ្រាន់តែជាការពិនិត្យមើលលទ្ធផលនៃការអប់រំដោយការវាយតម្លៃលើផលប្រយោជន៍របស់អប់រំផ្តល់ឲ្យគ្រប់វិស័យទាំងអស់នៃសិទ្ធិមនុស្សនោះទេ។

## ៦.១. សម្របសម្រួលសាលាឲ្យស្របតាមតម្រូវការរបស់កុមារ

គេឃើញមានជំរើសច្រើនទាក់ទងនឹងវិធីសាស្ត្រទាំងពីរគឺការអប់រំបញ្ចូលទាំងអស់គ្នា និងការអប់រំសំរាប់តម្រូវការពិសេស ហើយប្រទេសនីមួយៗប្រើប្រាស់វិធីសាស្ត្រខុសៗគ្នា។ ឧទាហរណ៍ គេអាចជ្រើសរើសយកប្រព័ន្ធអប់រំរដ្ឋដែលឯកភាពគ្នាមួយ ឬក៏ប្រព័ន្ធអប់រំដែលមានជំនាញច្រើនបែប។ ប្រទេសខ្លះតម្រូវឲ្យកុមារទាំងអស់ទទួលការអប់រំនៅសាលា និងប្រទេសមួយចំនួនទៀតអនុញ្ញាតឲ្យឪពុកម្តាយអប់រំកូនដោយខ្លួនឯង។

គុណសម្បត្តិ និងគុណវិបត្តិនៃវិធីទាំងពីរមានច្រើនដូចគ្នា។ ការស្រាវជ្រាវជាច្រើនត្រូវបានធ្វើដើម្បីពិនិត្យមើលថា តើស្តង់ដាសិទ្ធិមនុស្សអប្បបរមាបែបណា ដែលអាចបញ្ចូលទៅក្នុងវិធីនីមួយៗខាងលើ។ ប្រការនេះបង្ហាញពីភាពអាចបត់បែនបានរបស់ច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ វាមិនមានលក្ខណៈជាគ្រឿងផ្សំតែមួយមុខត្រូវគ្រប់មុខម្ហូបទាំងអស់នោះទេ។ ច្បាប់នេះតម្រូវឲ្យមានការវិភាគឲ្យបានច្បាស់លាស់អំពីស្តង់ដាសិទ្ធិមនុស្ស និងរួមបញ្ចូលគំរូខុសៗគ្នាដែលអាចយកមកអនុវត្តជាក់ស្តែងបាន។

វិធីសាស្ត្រសិទ្ធិមនុស្សចាំបាច់តម្រូវឲ្យមានការបញ្ជាក់ឲ្យបានច្បាស់លាស់ថា បុគ្គលម្នាក់គឺជាវត្ថុដែលមានសិទ្ធិស្មើគ្នា។ "ទាំងអស់គ្នាខុសគ្នា តែទាំងអស់គ្នាស្មើគ្នា" គឺជាពាក្យស្លោកដែលគេប្រើដើម្បីបញ្ជាក់ពីការប្តេជ្ញាចិត្តនេះ។ នៅក្នុងការអប់រំ លទ្ធផលសិក្សារបស់សិស្សនៅក្នុងការប្រលងដែលមានស្តង់ដាត្រឹមត្រូវគឺជាអាំងឌីកាទ័រដែលត្រូវប្រើប្រាស់ជាញឹកញាប់ដើម្បីវាយតម្លៃគុណភាពរបស់ប្រព័ន្ធអប់រំ។ វិញ្ញាសាប្រលងទាក់ទងនឹងមុខវិជ្ជាមួយចំនួនប៉ុណ្ណោះនៅក្នុងកម្មវិធីសិក្សា។ ជាទូទៅ គឺជាមុខវិជ្ជាដែលងាយគណនា និងអាចវាស់វែងបាន ដូចជា គណិតវិទ្យា និងវិទ្យាសាស្ត្រ។ ជាញឹកញាប់ គេប្រែក្លាយលទ្ធផលនេះឲ្យទៅជាតារាង

ស្តង់ដាជាតិ និងអន្តរជាតិ ហើយទាក់ទាញការយកចិត្តទុកដាក់ និងមានឥទ្ធិពលលើលទ្ធភាពរកការងារធ្វើរបស់សិស្ស។ និយមន័យដែលថា "ការអប់រំ" គឺជាការ "វិនិយោគ" ជាញឹកញាប់នាំមកនូវជោគជ័យដែលវាស់ដោយប្រាក់ខែដែលទទួលបានបន្ទាប់ពីការសិក្សា។ ស្ថានភាពអត់ការងារធ្វើរបស់និស្សិតអាចបង្ហាញពីភាពមិនស៊ីចង្វាក់គ្នានៃការអប់រំ និងពលកម្មទីផ្សារ។

បន្ថែមលើការផ្សព្វផ្សាយចំណេះដឹង ការអប់រំគឺជាយានសំរាប់បន្តដឹកជញ្ជូនគុណធម៌ និងវប្បធម៌ពីមួយជំនាន់ទៅមួយជំនាន់មួយទៀត។ តាមទស្សនៈសិទ្ធិមនុស្ស ប្រព័ន្ធអប់រំសិទ្ធិមនុស្សទាំងមូលត្រូវតែអនុលោមទៅតាមស្តង់ដាដែលទទួលស្គាល់ជាសកល ដែលរួមបញ្ចូលទាំងខ្លឹមសារអប់រំ និងគុណភាពរបស់ប្រព័ន្ធអប់រំត្រូវវាយតម្លៃទៅតាមចំណែកដែលការអប់រំបានផ្តល់ឲ្យមានការអនុវត្តសិទ្ធិផ្សេងទៀតនៅក្នុងសង្គម។

ក្នុងន័យនេះ ទោះបីជាប្រព័ន្ធអប់រំដែលមានបញ្ចូលខ្លឹមសារពិស្តារក៏ដោយ ក៏នៅតែមានកំហុសដោយសារការខកខានមិនបានលុបបំបាត់ការផ្សព្វផ្សាយបន្តឆ្លងជំនាន់ស្តីពីការប្រកាន់ពូជសាសន៍ ឬការភ័យខ្លាចចំពោះជនជាតិផ្សេង។ ប្រព័ន្ធអប់រំដាច់ដោយឡែកក៏អាចមានកំហុសដែរ ដោយសារការបំបែកបំបាក់សង្គម ឬបង្កឲ្យមានជម្លោះនៅក្នុងសហគមន៍។ ភាពមិនអាចបំបែកពីគ្នាបាននៃសិទ្ធិមនុស្សចាំបាច់ត្រូវវាយតម្លៃលើការចូលរួមចំណែករបស់អប់រំក្នុង ការពង្រីកសិទ្ធិមនុស្ស។ នេះគឺជាចំណុចដែលគេមិនទាន់ស្រាវជ្រាវឲ្យបានស៊ីជំរៅនៅឡើយ។ ហេតុផលសំខាន់មួយនៃការ មិនទាន់បានធ្វើ គឺការតម្រង់ទិសការអប់រំតាមផ្នែកដែលផ្ទុយទៅវិញវិធីអប់រំផ្អែកលើសិទ្ធិសង្កត់លើផ្នែកទូទៅទាំងអស់។ ចំណាប់អារម្មណ៍សំខាន់នៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិស្តីពីការលុបបំបាត់ការរើសអើងយេនឌ័រ និងពូជសាសន៍បង្ហាញពីបញ្ហាដែលត្រូវផ្តល់អាទិភាព។ លើសពីនេះទៀត បញ្ញត្តិដាក់លាក់ជាច្រើនសំរាប់ខ្លឹមសារនៃកម្មវិធីសិក្សាចង្អុលបង្ហាញអំពីចំណុចដែលត្រូវកែប្រែចាំបាច់នៅគ្រប់ផ្នែកទាំងអស់នៃវិស័យអប់រំដើម្បីលើកតម្កើងសិទ្ធិមនុស្ស។

ប្រែក្លាយសេចក្តីថ្លែងការណ៍ទាំងឡាយដែលមានចែងនៅក្នុងសន្ធិសញ្ញា និងកតិកាសញ្ញានានាឲ្យទៅជាការពិតកាន់តែងាយស្រួលជាងមុនដោយសំអាងលើបទពិសោធន៍ជាច្រើនដែលប្រមូលបានពីជុំវិញពិភពលោកក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ។ នេះបង្ហាញពីតម្រូវការដែលត្រូវផ្លាស់ប្តូរពីសម្ភារ (ថវិកា សាលា រៀន គ្រូ ឬការធ្វើតេស្ត) ទៅជាខ្លឹមសារ (សិទ្ធិទទួលការអប់រំ) ដើម្បីស្វែងយល់អំពីគុណភាពនៃការអប់រំ និងជំរុញការសន្ទនារវាងការអប់រំ និងសង្គមឲ្យកាន់តែស្និទ្ធស្នាល។

គ្មានគ្រឿងផ្សំដែលផលិតរួចស្រាប់ៗ ដែលត្រូវគ្រប់ទីកន្លែងនោះទេ។ ស្តង់ដាសិទ្ធិមនុស្សផ្តល់ការណែនាំស្តង់ដាសំខាន់ៗ និងនីតិវិធីដែលត្រូវប្រែក្លាយឲ្យទៅជាគំរូសមស្របសំរាប់សហគមន៍ ឬប្រទេសនីមួយៗ។ គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារបានរៀបរាប់ពីដំណើរការនេះដូចតទៅ :

"កិច្ចខិតខំប្រឹងប្រែងដើម្បីជំរុញការយល់ដឹង ការអត់ឱន និងមិត្តភាព ... មិនអាចស៊ីចង្វាក់គ្នាទាំងស្រុង ជាមួយគោលនយោបាយដែលបានបង្កើតឡើងដើម្បីអភិវឌ្ឍសេចក្តីគោរពរបស់កុមារចំពោះអត្តសញ្ញាណវប្បធម៌ ភាសា និងគុណធម៌សំរាប់ប្រទេសដែលកុមារកំពុងរស់នៅ ឬប្រទេសកំណើតរបស់កុមារទេ។ ប៉ុន្តែតាមពិតទៅ ផ្នែកមួយសំខាន់នៃមាត្រាទី ២៩ គួសបញ្ជាក់យ៉ាងច្បាស់ក្នុងការទទួលស្គាល់តម្រូវការវិធីសាស្ត្រ ដែល មានតុល្យការគ្នានៅក្នុងការអប់រំ និងវិធីដែលធ្វើឲ្យមានជោគជ័យនៅក្នុងការសម្របសម្រួលគុណធម៌សំបូរបែបតាមរយៈការចរចា និងគោរពចំពោះភាពខុសគ្នា"[៤៩]។

49. Committe on the Rights of the Child - The aims of education, General Comment 1, U.N. Doc. CRC/GC/2001/1 (2001)

## ៦.២. ពង្រឹងលទ្ធផលយូរអង្វែងនៃការអប់រំ

### ៦.២.១. លុបបំបាត់ពលកម្មកុមារ

ការចុះសច្ចាប័នច្រើនឡើងនៃសន្ធិសញ្ញាអង្គការពលកម្មពិភពលោកស្តីពីភាពមិនអត់ឱនគ្រប់ទម្រង់នៃពលកម្មកុមារ[៥០] និងការពង្រីកយ៉ាងឆាប់រហ័សនៃកម្មវិធី IPEC/ILO នៅក្នុងប្រទេសជាច្រើន[៥១] ផ្តល់ការគាំទ្រទាំងស្មារតី និងសម្ភារដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរក្នុងការអនុវត្តច្បាប់ពលកម្មកុមារ។

**ពលកម្មកុមារ**

ទំនាក់ទំនងរវាងការអប់រំ និងការងារទាមទារឲ្យមានការពិនិត្យឲ្យបានច្បាស់លាស់អំពីពេលវេលា គុណភាព និងការតម្រង់ទិស និងខ្លឹមសារនៃប្រព័ន្ធអប់រំរបស់ប្រទេសនីមួយៗទាក់ទងនឹងលទ្ធភាពរបស់ប្រទេសនេះក្នុងការរៀបចំសិស្សឲ្យរកប្រាក់ចំណូល។ ស្ថានភាពនៃភាពគ្មានការងារធ្វើរបស់និស្សិតរៀនចប់បញ្ជាក់យ៉ាងច្បាស់អំពីតម្រូវការធ្វើឲ្យការអប់រំមានទំនាក់ទំនងនឹងពលកម្មទីផ្សារ (រួមបញ្ចូលទាំងការរកស៊ីដោយខ្លួនឯង និងនៅផ្នែករដ្ឋ និងឯកជន)។

**អាយុអប្បបរមា អាចរក ការងារធ្វើបាន**

ក្របខ័ណ្ឌសិទ្ធិមនុស្សអន្តរជាតិផ្តល់ការណែនាំសំខាន់ៗដោយផ្សារភ្ជាប់អាយុឈប់រៀន និង អាយុអប្បបរមាអាចធ្វើការបានដែលកំណត់ដោយអង្គការពលកម្មពិភពលោកនៅឆ្នាំ ១៩២១ គឺនៅអាយុ១៤ ឆ្នាំ។ នៅ ឆ្នាំ ១៩៤៦ អង្គការពលកម្មពិភពលោកបានបង្កើនអាយុដល់ ១៦ ឆ្នាំ។ ការប្តេជ្ញាចិត្តផ្លូវច្បាប់សំខាន់ៗមួយចំនួនត្រូវធ្វើឡើងនៅឆ្នាំ ១៩៧៣ នៅក្នុងសន្ធិសញ្ញាអាយុអប្បបរមារបស់អង្គការពលកម្មពិភពលោក ហើយប្រទេស ដែលបានផ្តល់សច្ចាប័នទាំងអស់កំណត់អាយុអប្បបរមាដែលអាចធ្វើការបាន។ ទាំងអស់នេះមានបញ្ចូលនៅក្នុងតារាងទី ១៤ សំរាប់ប្រទេសដែលជាដៃគូរបស់សន្ធិសញ្ញានេះ។

និយមន័យខុសគ្នានៃការអប់រំបឋមភូមិ និង/ឬមូលដ្ឋាន និងរយៈពេលខុសគ្នា និងកំរិតនៃការពង្រឹងការសិក្សាដោយខានមិនបានធ្វើឲ្យការបែងចែកអាយុកាន់តែមានសារៈសំខាន់ឡើង។ ព័ត៌មានបែបនេះមានសារៈសំខាន់ណាស់នៅក្នុងការលុបបំបាត់ទម្រង់ទាំងឡាយនៃពលកម្មកុមារ និងក្នុងការផ្តល់ការអប់រំចំពោះកុមារដែលកំពុងធ្វើការក៏ដូចជាការប្រយុទ្ធប្រឆាំងនឹងការរៀបការកុមារ។ បញ្ហាទាំងឡាយដែលកើតចេញពីច្បាប់អាយុអប្បបរមាមិនស៊ីចង្វាក់គ្នាត្រូវបានរៀបរាប់នៅក្នុងឆ្នាំ ១៩៩៦ នៅប្រទេសថៃ (ការអប់រំដោយកាតព្វកិច្ចត្រូវពន្យារពី ៦ ទៅ ៩ ឆ្នាំ និងក្រោយមកទៅ ១៤ ឆ្នាំ នៅដើមឆ្នាំ ២០០៤):

អាយុសិស្សនៅកំរិតអប់រំដោយខានមិនបានបង្កើតបញ្ហាសំរាប់កុមារក្នុងការរកការងារធ្វើនៅពេលកុមារប្រៀបធៀបជាមួយអាយុអប្បបរមាដែលអាចធ្វើការបាន។ កុមារមានអាយុប្រហែលតែ ១១ ឬ ១២ ឆ្នាំ

---

*50 សន្ធិសញ្ញាអង្គការពលកម្មពិភពលោកលេខ ១៨២ ទាក់ទងនឹងការហាមឃាត់ និងសកម្មភាពបន្ទាន់ដើម្បីលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារកំណត់អ្នកមានអាយុតិចជាង ១៨ ឆ្នាំថាជាកុមារ។ ការមានសិទ្ធិទទួលបានការអប់រំមូលដ្ឋានដោយមិនបង់ប្រាក់ត្រូវបានគេធ្វើឲ្យទូលំទូលាយដើម្បីរួមបញ្ចូលកុមារទាំងអស់ ដែលត្រូវបានគេយកចេញពីពលកម្មកុមារធ្ងន់ធ្ងរ ទោះបីជាពួកគេមានអាយុ ច្រើនជាងអាយុចូលរៀនក៏ដោយ។ នៅខែមេសា ឆ្នាំ ២០០៣ សន្ធិសញ្ញានេះត្រូវបានផ្តល់សច្ចាប័នដោយប្រទេសចំនួន ១៣៦។*

*51 របាយការណ៍ពិភពលោកទី ១ ក្រោមការប្រកាសរបស់អង្គការពលកម្មពិភពលោកស្តីពីសិទ្ធិ និងគោលការណ៍មូលដ្ឋាននៅកន្លែង ធ្វើការដែលការលុបបំបាត់ពលកម្មកុមារមានប្រសិទ្ធិភាព ត្រូវបានគេជ្រើសរើសធ្វើជាប្រភេទមួយក្នុងចំណោមទាំង ៤ ប្រភេទដែល ត្រូវតាមដាន ដោយមានចុះបញ្ជីប្រទេសចូលរួមចំនួន ៧៥។ នៅអាស៊ី ប្រទេសជំនួន ១១ បានចុះអនុស្សរណៈនៃការយល់ដឹងពី IPEC (បង់ក្លាដេស កម្ពុជា ឥណ្ឌា ឥណ្ឌូណេស៊ី ឡាវ ណេប៉ាល់ ម៉ុងហ្គោលី ប៉ាគីស្ថាន ពីលីពីន សេរីឡាំងកា និងថៃ)។ ប្រទេសចិន និង វៀតណាមបានចុះបញ្ជីជាសមាជិករងនៃ IPEC . ការិយាល័យពលកម្មអន្តរជាតិ — អនាគតដែលគ្មានពលកម្មកុមារ។ របាយការណ៍ពិភពលោកស្ថិតនៅក្រោមការតាមដានបន្ត ដោយការប្រកាសរបស់អង្គការពលកម្មពិភពលោកស្តីពីសិទ្ធិ និងគោលការណ៍មូលដ្ឋាននៅកន្លែងធ្វើការ។ សន្និសិទ្ធពលកម្មអន្តរជាតិលើទី ៩០ (២០០២) របាយការណ៍ទី ១ (ខ) ទំពរ ១៣៧។*

**តារាងទី ១៤ : អាយុអប្បបរមាស្របច្បាប់អាចធ្វើការបាននៅតាមបណ្ដាប្រទេសនានា[៥២]**

| | |
|---|---|
| 14 | Angola, Argentina, Bahamas, Belize, Benin, Bolivia, Botswana, Cambodia, Cameroon, Central African Republic, Colombia, Congo/Brazzaville, Congo/Kinshasa, Dominican Republic, Ecuador, Egypt, El Salvador, Equatorial Guinea, Eritrea, Ethiopia, Gambia, Guatemala, Honduras, Malawi, Mauritania, Namibia, Nepal, Nicaragua, Niger, Panama, Peru, Rwanda, Sri Lanka, Sudan, Tanzania, Togo, Uganda, Venezuela, Yemen, Zimbabwe |
| 15 | Austria, Barbados, Belgium, Bosnia and Herzegovina, Burkina Faso, Chile, Costa Rica, Croatia, Cuba, Cyprus, Denmark,Dominica, Fiji, Finland, Georgia, Germany, Greece, Guyana, Iceland, Indonesia, Iraq, Ireland, Israel, Italy, Japan, Kuwait, Lesotho, Libya, Luxembourg, Macedonia, Madagascar, Malaysia, Mali, Mauritius, Mongolia, Morocco, Netherlands, Nigeria, Norway, Philippines, Poland, Republic of Korea, Senegal, Seychelles, Slovakia, Slovenia, South Africa, Swaziland, Sweden, Switzerland, Syria, Turkey, United Arab Emirates, Uruguay, Yugoslavia, Zambia |
| 16 | Albania, Algeria, Antigua and Barbuda, Azerbaijan, Belarus, Brazil, Bulgaria, Burundi, China, France, Hungary, Jordan, Kazakhstan, Kenya, Kyrgyzstan, Lithuania, Malta, Moldova, Papua New Guinea, Portugal, Romania, Russia, San Marino, Spain, Tajikistan, Tunisia, Ukraine, United Kingdom |

ប៉ុណ្ណោះនៅពេលពួកគេបញ្ចប់បឋមសិក្សា។ អាយុនៅក្មេងណាស់សំរាប់ពលកម្មទីផ្សារ ដែលតម្រូវឲ្យកុមារមានអាយុ ១៣ ឆ្នាំ ពេលចូលធ្វើការដំបូង។ ដោយហេតុថា មានកុមារតែជាង៣ក់កណ្ដាលប៉ុណ្ណោះបន្តការសិក្សានៅមធ្យមសិក្សាកាលពីទសវត្សរ៍កន្លងមកកុមារជាច្រើនបានចូលធ្វើការដោយខុសច្បាប់។ ក្រៅពីនេះ ពលកម្មកុមារក្លាយជាប្រភពដ៏សំខាន់នៃពលកម្មគ្មានកម្រៃនៅតំបន់ស្រែចំការដែលឪពុកម្ដាយមិនអាចរកប្រភពពលកម្មណាមកជំនួសបាន[៥៣]។

## ៦.២.២. លុបបំបាត់អាពាហ៍ពិពាហ៍កុមារ

ការខិតខំលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងកុមារី និងស្ត្រីត្រូវបានធ្វើឡើងដោយសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនិងគោលនយោបាយអប់រំសំរាប់ទាំងអស់គ្នា។ មាន យុទ្ធសាស្ត្រសកលជាច្រើនពង្រឹងវិធីសាស្ត្រទាំងនេះដែលរួមមាន ការអភិវឌ្ឍកិច្ចសហប្រតិបត្តិការដើម្បីលុបបំបាត់ភាពក្រីក្រ។ យុទ្ធសាស្ត្រទាំងនេះទទួលការគាំទ្រទាំងក្នុងរដ្ឋាភិបាល អន្តររដ្ឋាភិបាល និង ស្ថាប័នហិរញ្ញវត្ថុដើម្បីអភិវឌ្ឍន៍ផងដែរ។

ការប្ដេជ្ញារបស់អន្តរជាតិដើម្បីលុបបំបាត់វិសមភាពយេនឌ័រនៅក្នុងបឋមសិក្សា និងមធ្យមសិក្សានៅមុនឬត្រឹមឆ្នាំ ២០០៥ គឺជាគោលដៅដែលត្រូវសម្រេចឲ្យ បាននៅរយៈពេលលើកទី១នៅក្រុងដាកា។ ដូច្នេះថ្ងៃនេះដល់ពេលដែលត្រូវតាមដានពិនិត្យការរីកចំរើន ឆ្ពោះទៅសម្រេចគោលដៅនេះនៅថ្នាក់ជាតិហើយ។ គោលបំណងគឺកត់សំគាល់ឧបសគ្គដែលនៅសេសសល់ទាំងឡាយ និងខិតខំធ្វើឲ្យសម្រេចយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពដើម្បីធានាសម្រេចគោលដៅក្នុងពេល វេលាមួយដែលបានព្រមព្រៀងគ្នា។

**វិសមភាពយេនឌ័រគិតជាតួលេខ**

កិច្ចខិតខំប្រឹងប្រែងដើម្បីប៉ះប៉ូវនូវការចុះឈ្មោះដែលមិនមានសមភាពនៅបឋមសិក្សាបានបញ្ចូលការបំផុសឲ្យមានលក្ខខណ្ឌលើកទឹកចិត្តចំពោះឪពុកម្ដាយ និងបង្កើតលទ្ធភាព និងឱកាសឲ្យកូនស្រីបានចូលរៀនច្រើន។ ចលនានេះបានរួមបញ្ចូលលក្ខខណ្ឌតម្រូវឲ្យមានការចូលរៀនរបស់ក្មេងស្រីចំនួនប៉ុន្មានភាគរយជាក់លាក់ ការរៀបចំសាលាពិសេសសំរាប់ក្មេងស្រី និងការជ្រើសរើស និងបណ្ដុះបណ្ដាលគ្រូស្រី។ បទពិសោធន៍កន្លងមកបង្ហាញឲ្យឃើញថា ការផ្ដួចផ្ដើមគំនិតបង្កើនការចូលរៀនរបស់ក្មេងស្រី និងការជ្រើសរើសគ្រូស្រីឲ្យបង្កើនមានលទ្ធផលរយៈពេលខ្លីប៉ុណ្ណោះ ហើយពុំមាននិរន្តរភាពទេ។ ហេតុផលគឺថា ការជ្រើសរើសគ្រូស្រីច្រើនសំរាប់កុមារក្មេងៗ វាជួយទៅនឹងចំនួនស្ត្រីតិចតួចប៉ុណ្ណោះដែលកាន់មុខតំណែងធំជាអ្នកសម្រេចចិត្ត។

ខ្លឹមសារសង្ខេបដកស្រង់ចេញពីរបាយការណ៍ រដ្ឋាភិបាលក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សតែងលើកឡើងអំពីសភាពការណ៍នេះ។ នៅប្រទេសមីយ៉ាន់ម៉ា *"គ្រូស្រីមានចំនួនច្រើនជាងគ្រូប្រុសនៅបឋមសិក្សា និង*

---

52 រដ្ឋដែលក្លាយជាភាគីនៃសន្ធិសញ្ញាអាយុអប្បបរមានៃអង្គការពលកម្មពិភពលោកឆ្នាំ ១៩៧៣ (លេខ ១៣៨) ត្រូវតែប្រកាសជាផ្លូវការពីអាយុអប្បបរមាអាចបំពេញការងារ នៅពេលផ្ដល់សច្ចាប័នដល់សន្ធិសញ្ញានេះ។ មានការផ្ដល់សច្ចាប័នចំនួន ១២៤ នៅត្រឹម ខែមេសា ឆ្នាំ ២០០៣ និងអាយុអប្បបរមាអាចបំពេញការងារបានចេញពីសន្ធិសញ្ញានេះ។

53 Initial report under the Child Rights Convention, 1996, U.N.Doc. CRC/C11/Add.13. para.115

**តារាងទី ១៥ : ឧបសគ្គក្រៅសាលាដែលរារាំងដល់ការ អប់រំរបស់កុមារី**

| ប្រទេស | ការងារផ្ទះដែលគ្មានកម្រៃ | អាពាហ៍ពិពាហ៍កុមារ | ការមានផ្ទៃពោះ |
|---|---|---|---|
| បង់ក្លាដែស | | X | |
| ព្រុយណេ | | X | |
| ឈីលី | | | X |
| សាធារ.អាព្រិចកណ្តាល | | X | |
| សាធារ. ដូមីកាំង | | | X |
| អេចូពី | | X | |
| ហ្កាំប៊ី | | X | X |
| ឥណ្ឌា | | X | X |
| ឥណ្ឌូណេស៊ី | | X | X |
| ជ័រដានី | | X | X |
| កៀហ្ស៊ីស្តង់ | | X | |
| លីបាណុន | | X | X |
| ឡេសូថូ | | | X |
| ណេប៉ាល់ | | X | X |
| នីហ្សេ | | X | X |
| ប៉ាគីស្ថាន | | X | X |
| ប៉ាពួញូហ្គីនី | X | X | |
| ប៉ារ៉ាហ្កាយ | | | X |
| អារ៉ាប់សាអូឌី | | X | |
| កោះសូឡូម៉ុង | | X | |
| ស្រីលង្កការ | X | X | |
| ស៊ីរីយ៉ា | | X | |
| តាជីគីស្តង់ | | X | |
| តង់ហ្សានី | X | | X |
| តូហ្គូ | | X | |
| អ៊ូបេគីស្តង់ | | X | |

**ប្រភព : របាយការណ៍រដ្ឋាភិបាលក្នុងសន្ធិសញ្ញាស្តីពីសិទ្ធិកុមារ និងសន្ធិសញ្ញាស្តីពីការលុបបំបាត់ការរើស**

*មធ្យមសិក្សា។ ឆ្នាំសិក្សា ១៩៩៦–១៩៩៧ មានគ្រូស្រីចំនួន ៧៩ភាគរយនៅ បឋមសិក្សា និងគ្រូប្រុស ៧៥ ភាគរយនៅ មធ្យមសិក្សា។"*[៥៤] ប្រទេសពីលីពីន "តំណាងស្ត្រីមិនគ្រប់គ្រាន់នៅកាន់មុខតំណែងកំពូលៗនៅគ្រប់វិស័យទាំងអស់ នៅតែមាននៅឡើយហើយធ្វើឲ្យប៉ះពាល់ដល់ជីវភាពប្រជាជនថ្នាក់ក្រោម។ សភាពបែបនេះគេឃើញមានច្រើននៅក្នុងវិស័យអប់រំដែលមានស្ត្រីច្រើនលើសលុបធ្វើជាគ្រូបង្រៀន តែមុខតំណែងស្ត្រីនៅថ្នាក់លើក្នុងវិស័យនេះមានតិចណាស់"។[៥៥]

ការលំបាកក្នុងការលុបបំបាត់វិសមភាពយេនឌ័របណ្តាលមកពីឧបសគ្គនៅក្រៅសាលា និងផ្នែកអប់រំ។ ដូច្នេះ គោលការណ៍នៃការមិនអាចបំបែកបាននៃសិទ្ធិមនុស្សផ្តល់នូវការណែនាំមានសារប្រយោជន៍ជាច្រើន ពីព្រោះវាតម្រូវឲ្យមានការតាមដានត្រួតពិនិត្យឋានៈស្របច្បាប់របស់កុមារី និងស្ត្រីនៅក្នុងសង្គម និងកត្តាទាំងឡាយដែលនាំឲ្យមានឋានៈបែបនេះ។

នៅក្នុងបណ្តាប្រទេសជាច្រើនទំនាក់ទំនងរវាងបុគ្គល និងសង្គមគ្រួសារ និងសហគមន៍ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ច្បាប់ សាសនា និងទំនៀមទំលាប់សង្គម។ នៅក្នុងសង្គម ដែលយកការកិច្ចជាធំ តម្លៃនៃការរស់នៅជាសហគមន៍មានវិសាលភាពធំធេងជាងសិទ្ធិបុគ្គល។ ដូច្នេះ កត្តាដែលមានទំនាក់ទំនងជិតស្និទជាច្រើនកំណត់យុទ្ធសាស្ត្រសកលដែលមានបំណងធ្វើឲ្យមានសមភាពយេនឌ័រ។ កត្តាទាំងឡាយដែលរដ្ឋាភិបាលជាច្រើនបានផ្តល់នៅក្នុងរបាយ–ការណ៍នៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សមានចុះក្នុងតារាង ១៥។

វិធីដែលក្មេងស្រីអាចប្រែក្លាយការអប់រំឲ្យទៅជាការប្រើប្រាស់ជាក់ស្តែង ជាពិសេសក្នុងការប្រើប្រាស់សិទ្ធិផ្នែកសេដ្ឋកិច្ចមានឥទ្ធិពលលើប្រសិទ្ធភាពអប់រំ និងបញ្ជាក់បន្ថែមពីការអប់រំដោយផ្អែកលើសិទ្ធិ និងបញ្ចូលគ្រប់វិស័យទាំងអស់។ ភាពមិនស៊ីចង្វាក់គ្នានៃច្បាប់អប់រំក្បួនច្បាប់គ្រួសារ និងច្បាប់សេដ្ឋកិច្ច និងពលកម្មធ្វើឲ្យមានការកែប្រែ ពុំមានប្រសិទ្ធភាព និងមិនមាននិរន្តរភាព។[៥៦]

54 Initial report of Myanmar under the Convention on the Elimination of All Forms of Discrimination against Women, CEDAW/C/MMR/1, 1999.

55 Fourth periodic report of the Philippines under the Convention on the Elimination of All Forms of Discrimination against Women, 1996, U.N. Doc. CEDAW/C/PHI/4, para. 162.

56 Economic and Social Commission for Asia and the Pacific - Human Rights and Legal Status of Women in the Asian and Pacific Region, United Nations, New York, 1997, p. 42.

ការទាមទារឲ្យកុមារីធ្វើការងារផ្ទះ និងកម្មវិធីក្រៅសាលាជាច្រើនទៀត គឺជាកត្តាសំខាន់បំផុតដែលធ្វើឲ្យក្មេងស្រីឈប់រៀន។ ក្មេងស្រីដែលត្រូវធ្វើការងារផ្ទះត្រូវកែប្រែពេលវេលាទៅសាលាឲ្យស៊ីគ្នានឹងពេលវេលាដែលត្រូវធ្វើការងារផ្ទះ និងការបង្កបង្កើនផល និងជីវភាពគ្រួសារ។ ដោយហេតុថាគ្រួសារក្រីក្រត្រូវពឹងពាក់លើសមាជិកគ្រួសារដើម្បីធ្វើការចិញ្ចឹមជីវិតកុមារីត្រូវផ្ដល់អាទិភាពដល់ការងារជាងការសិក្សា។ បទពិសោធន៍របស់អង្គការពលកម្មពិភពលោកក្នុងការរំដោះកុមារឲ្យចេញផុតពីពលកម្ម ហើយនាំ កុមារឲ្យចូលរៀនវិញបានបង្ហាញពីអត្ថប្រយោជន៍នៃការហាមឃាត់ និងថ្កោលទោសដល់ការវិនិយោគទាំងឡាយដែលមិនគោរពសិទ្ធិមនុស្ស។[៥៧]

ពន្យារពេលការសិក្សារបស់ក្មេងស្រីឲ្យរៀនបានកាន់តែខ្ពស់ជួយឲ្យមានជោគជ័យក្នុងការពន្យារពេលរៀបការ និងការមានកូន។ ការអប់រំបំពេញបន្ថែម និងពង្រីងការខិតខំប្រឹងប្រែងលុបបំបាត់អាពាហ៍ពិពាហ៍កុមារ។ ទោះបីជាយ៉ាងនេះក៏ដោយភាពខុសគ្នាយ៉ាងខ្លាំង រវាងព័ត៌មានស្ថិតិ និងការពិតជាក់ស្តែងគួរឲ្យព្រួយបារម្ភណាស់ទាក់ទងនឹងអាពាហ៍ពិពាហ៍កុមារ។ ករណីមិនស្របច្បាប់នានាមិនត្រូវបានកត់ត្រាទុកនោះទេ ដូច្នេះអាពាហ៍ពិពាហ៍ដែលបានកត់ត្រាជាផ្លូវការ គឺជាអាពាហ៍ពិពាហ៍ដែលត្រឹមត្រូវតាមច្បាប់។

| តារាងទី ១៦ : អាយុរៀបការអប្បបរមា | | |
|---|---|---|
| អាយុស្របច្បាប់អប្បបរមារបស់ក្មេងស្រីទាបជាង ក្មេងប្រុស | ប្រទេសអនុវត្តតាមច្បាប់សាសនា និងប្រពៃណី | មិនមានកំណត់អាយុអប្បបរមាសំរាប់រៀបការ |
| អូទ្រីស ១៥/១៨ | បង់ក្លាដែស | បេនីន |
| បូលីវី ១៤/១៦ | ប៊ីគីណាហ្វាសូ | ឆាដ |
| ឈីលី ១២/១៤ | អេចូពី | កូម៉ូរ៉ូស |
| សាធារ. ដូមីកាំង ១៥/១៦ | Guinea-Bissau | កូឌីវ៉រ |
| ហ្គាតេម៉ាឡា ១៤/១៦ | ឥណ្ឌា | ហ្គាណា |
| ហុងកុង ១៥/១៦ | ឥណ្ឌូណេស៊ី | ហ្គីណេជា |
| គុយវ៉ែត ១៥/១៧ | ម៉ាលី | Guinea |
| ម៉ិចហ្ស៊ិចកូ ១៤/១៦ | ណាមីប៊ី | Guinea-Bissau |
| នីការាហ្គ័រ ១១៤/១៥ | ស្រីលង្កា | កេនញ៉ា |
| ម៉ូលដូវ៉ា ១៤/១៦ | តង់ហ្សានី | ឡេសូថូ |
| ST. Vincent ១៥/១៦ | ហ្សាំប៊ី | ម៉ាឡាវី |
| អាព្រិចខាងត្បូង ១២/១៤ | ហ្ស៊ីបាវេ | ម៉ាលឌីវ |
| ស៊ូរីណាម ១៣/១៥ | | ម៉ូរីតានី |
| ទ្រីនីដាត និងតូបាហ្គូ ១២/១៤ | | នីហ្សេ |
| | | អារ៉ាប់សាអូឌី |
| | | សេរ៉ាលេអូន |
| | | ស៊ូដង់ |
| ប្រភព : របាយការណ៍រដ្ឋាភិបាលក្នុងសន្ធិសញ្ញាស្តីពីសិទ្ធិកុមារ និងសន្ធិសញ្ញាស្តីពីការលុបបំបាត់ការរើស | | |

ការរៀបការកុមារគឺជាឧបសគ្គធំធេងចំពោះការសិក្សារបស់កុមារ ពីព្រោះអាយុអប្បបរមាដែលកុមារអាចរៀបការបាននៅក្មេងណាស់ដូចដែលតារាងទី ១៦ បង្ហាញ។ ជួនកាលពុំមានអាយុអប្បបរមាទេ។ ពិសេសជាងនេះទៀត ឪពុកម្តាយចាត់ទុកការវិនិយោគលើការសិក្សារបស់កូនស្រីជាការខាតបង់ប្រាក់កាស។ នេះជាផ្នត់គំនិតដែលទទួលឥទ្ធិពលពីទំនៀមទំលាប់ចាស់។ នៅប្រទេសបង់ក្លាដេស *"ការរៀបការកូនស្រីគឺជាបន្ទុកប្រាក់កាសដ៏ធ្ងន់ចំពោះឪពុកម្តាយខាងស្រី ដូច្នេះ ឪពុកម្តាយគិតថា ការវិនិយោគលើការអប់រំកូនស្រីនឹងមិនមានប្រយោជន៍សំរាប់គ្រួសារទេ ប៉ុន្តែនឹងផ្តល់ផលប្រយោជន៍ដល់គ្រួសារប្តី និងសាច់ថ្លៃ"*។[៥៨]

**អាពាហ៍ពិពាហ៍កុមារ**

ប្រឡោះតារាងខាងឆ្វេងនៃតារាងទី ១៦ រាយឈ្មោះប្រទេសដែលអាយុរៀបការអប្បបរមានៅក្មេងពេកដែលជាឧបសគ្គរារាំងដល់ការសិក្សារបស់ក្មេងស្រី។ តារាងក៏បង្ហាញពីការរើសអើងក្នុងការរៀបការកូនដោយកំណត់អាយុកូនស្រីឲ្យក្មេងជាងកូនប្រុស។ ប្រឡោះតារាងកណ្តាលមានរាយឈ្មោះប្រទេស ដែលមានច្បាប់ខុសគ្នារបស់រដ្ឋ សាសនា និងទំនៀមទំលាប់ ទោះបីជាប្រទេសនោះបានប្តេជ្ញាផ្តល់សិទ្ធិស្មើគ្នាសំរាប់កុមារី និងស្ត្រីក៏ដោយ។ ប្រឡោះតារាងខាងស្តាំរាយឈ្មោះប្រទេស ដែលគ្មានអាយុរៀបការអប្បបរមា។ ទាំងនេះជាប្រទេសដែលក្មេងស្រីអាចរៀបការដោយស្របច្បាប់តាំងពីមុនរៀននៅបឋមសិក្សា ឬកំពុងរៀនបឋមសិក្សា។

57 The Memorandum of Understanding between the Bangladesh Garment Manufacturers and Export Association with UNICEF and the ILO of 4 July 1995, and the Partners' Agreement to Eliminate Child Labour in Soccer Ball Industry in Pakistan between the Sialkot Chamber of Commerce and Industry, the ILO and UNICEF of 14 February 1997.

58 CRC/C/3/Add.38, 1995, para. 52.

តារាងទី ១៦ ចង្អុលបង្ហាញពីការលំបាកក្នុងការត្រួតពិនិត្យអាពាហ៍ពិពាហ៍កុមារទូទាំងពិភពលោក។ ផ្ទុយទៅនឹងការប្តេជ្ញាចិត្តសកលក្នុងការលុបបំបាត់ពលកម្មកុមារ អាពាហ៍ពិពាហ៍កុមារពុំមានដូចគ្នារវាងសាធារណៈជន និងរវាងរដ្ឋ និងរដ្ឋទេ។ ទោះបីពាក្យពេចន៍មានចែងក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សទាមទារឲ្យភាគីទាំងអស់រារាំងអាពាហ៍ពិពាហ៍កុមារ ការអនុវត្តជាក់ស្តែងនៅមានកំរិតខ្វះខាតជាច្រើន។ កតិកាសញ្ញាស្តីពីការលុបបំបាត់ការរើសអើងគ្រប់ទម្រង់ប្រឆាំងនឹងស្ត្រីមិនបានគាំទ្រឲ្យបានពេញទំហឹងដើម្បី (១) ធ្វើឲ្យអំណាចសាសនា និងច្បាប់ទំលាប់ប្រពៃណីចុះខ្សោយ និង(២)លើកកំពស់សិទ្ធិក្មេងស្រី និងស្ត្រីលើបញ្ហារៀបការ និងជីវិតគ្រួសារ។[៥៩]

កតិកាសញ្ញាស្តីពីសិទ្ធិកុមារក៏មានកង្វះខាតក្នុងការប្តេជ្ញាចិត្តប្រហាក់ប្រហែលគ្នាដែរ។ ប្រទេសមួយចំនួននៅស្ទាក់ស្ទើរក្នុងការធ្វើវិសោធនកម្មច្បាប់ និងការអនុវត្តជាក់ស្តែងក្នុងការធ្វើឲ្យអាយុស្របច្បាប់របស់កុមារដែលនៅរៀន ជាពិសេសក្មេងស្រីមិនអាចរៀបការបាន។[៦០] គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារតែងរំលឹករដ្ឋាភិបាលជារឿយៗអំពីការចាំបាច់តម្រូវឲ្យមានសិទ្ធិស្មើគ្នារវាងក្មេងស្រី/ស្ត្រី និងក្មេងប្រុស/បុរស។ នៅប្រទេសឥណ្ឌា *"ឋានៈបុគ្គលនៅតាមតំបន់បន្តធ្វើឲ្យមានវិសមភាពយេនឌ័រនៅក្នុងសង្គមដូចជា ការរៀបការ ជាដើម"*។[៦១] នៅប្រទេសបង់ក្លាដេស អាយុរៀបការអប្បបរមាតាមច្បាប់ ត្រូវបានកំណត់នៅត្រឹមអាយុ ១៨ ឆ្នាំ ប៉ុន្តែច្បាប់នេះមិនត្រូវបានអនុវត្តចំពោះប្រជាពលរដ្ឋគ្រប់រូបទេ។ ព័ត៌មានស្ថិតិផ្លូវការបង្ហាញថា ក្មេងស្រីអាចរៀបការបានទាំងក្មេងអាចមានអាយុត្រឹម ១០ ឆ្នាំក៏មាន ឬអាចក្មេងជាងនេះទៀតផង។ កុមារីជាច្រើនមានកូនតាមផ្លូវច្បាប់នៅពេលដែលពួកគេនៅជាក្មេងស្រីនៅឡើយ :

*"ក្នុងចំណោមអ្នករៀបការទាំងអស់ – ២៦ភាគរយមានអាយុពី ១០ ទៅ ១៤ ឆ្នាំ និង ៣៨ភាគរយមាន អាយុពី ១៥ ទៅ ១៩ ឆ្នាំ ប្រើប្រាស់វិធីពន្យារកំណើត ... ៥ ភាគរយនៃអ្នកមានអាយុពី ១០ ទៅ ១៤ ឆ្នាំ និង ៤៨ ភាគរយនៃអ្នកមានអាយុ ១៥ ទៅ ១៩ ឆ្នាំជាអ្នករៀបការហើយ"*។[៦២]

"នៅក្នុងប្រទេសមួយចំនួនដែលអនុវត្តតាមច្បាប់សាសនាពុំមានអាយុរៀបការអប្បបរមាទេ។ នៅប្រទេសប្រ៊ុយណេ *"ការរួមភេទដោយបុរសជាមួយនឹងប្រពន្ធគាត់ –ប្រពន្ធមានអាយុច្រើនជាង ១៣ ឆ្នាំ មិនត្រូវបានគេចាត់ទុកថាជាការចាប់រំលោភផ្លូវភេទទេ"*។[៦៣] ភាពក្រីក្រធ្វើឲ្យការចិញ្ចឹមកូនមានការលំបាកណាស់ : *"នៅ ប្រទេសឥណ្ឌូណេស៊ី ពីលីពីន និងវៀតណាម ជនក្រីក្របំផុតមានឱកាសអាចមានកូនចំនួន ៧ ដងច្រើនជាងអ្នក ដែលមានជីវភាពធូរធារ"*។[៦៤]

ការអប់រំដែលមានរយៈពេលយូរធ្វើឲ្យកំណើន ប្រជាជនយឺត និងមានកុមារតិចប៉ុណ្ណោះដែលត្រូវទទួលការអប់រំនៅពេលអនាគត។ ទំនាក់ទំនងរវាងការអប់រំស្ត្រី និងការមានកូនគឺជាទំនាក់ទំនងអវិជ្ជមាន ពីព្រោះស្ត្រីដែលមានការអប់រំកាន់តែខ្ពស់មានកូនកាន់តែតិច។ ការអប់រំសុខភាពផ្លូវ ភេទត្រូវបានអនុវត្តនៅប្រទេសមួយចំនួននៅក្នុងពិភព លោក។ ឧទាហរណ៍ ប្រទេសស៊ីម្ពាបូវេបង្ហាញពីនិន្នាការប្រែប្រួលនេះ :

---

59 Tomasevski, K. - A Handbook on CEDAW, the Convention on the Elimination of All Forms of Discrimination against Women , Swedish Ministry for Foreign Affairs/Sida, Stockholm, 1999, pp. 16 and 37.

60 Tomasevski, K. - Women, in: Eide, A. Et al. (eds.) - Economic, Social and Cultural Rights , Martinus Nijhoff Publishers, Dordrecht, 1995, pp. 275-281.

61 CRC/C/94, 2000, para. 64.

62 CRC/C/65/Add.22, 2001, paras. 208 and 222.

63 CRC/C/61/Add.5, 2001, paras. 35 and 38.

64 UNFPA State of the World Population 2002 , New York, 2003, p. 37.